Rb>k¼e l x010>027¼07 KCb>GK>Bs

ភ្នំពេញ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៧

bNgrbs elak Xm sta tNagKNbkSsm rgS mneKarB tamkarRbK l sTrbsedImbNg

នៅថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០០៧ គ.ជ.ប បានចេញលិខិតមួយឆ្លើយតបទៅនឹងបណ្តឹងរបស់តំណាងគណបក្សសម រង្ស៊ី ដែលបានប្តឹងចៅសង្កាត់ បឹងព្រលឹត ក្រុងភ្នំពេញ ពីបទរារាំងប្រជាពលរដ្ឋមិនឱ្យចុះឈ្មោះបោះឆ្នោត ។

ក្នុងលិខិតដែលចុះហត្ថលេខាដោយ ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានសរសេរថា បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះ គ.ជ.ប បានពិនិត្យយ៉ាងយកចិត្តទុកដាក់ ហើយឃើញថា កម្មវត្ថុនៃបណ្តឹងរបស់គណបក្សសម រង្ស៊ី មិនគោរពតាមការប្រគល់សិទ្ធិរបស់ដើមបណ្តឹង ដូច្នេះ គ.ជ.ប មិនអាចទទួលយកបណ្តឹងនេះមកដោះស្រាយបានទេ ។

ក្នុងលិខិតដដែលនេះបានបញ្ជាក់ថា ឈ្មោះ ហ៊ឹម ច័ន្ទគ្រីស្នា ត្រូវទៅបង្ហាញខ្លួនដោយផ្ទាល់នៅចំពោះមុខចៅសង្កាត់ បឹងព្រលឹត ដោយនាំយកមកជាមួយឯកសារផ្លូវការ និងសាក្សី ដើម្បីសុំបញ្ជាក់ទីលំនៅ សម្រាប់ចុះឈ្មោះបោះឆ្នោតរហូតដល់ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៧ ។

សូមរំលឹកថា កាលពីថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៧ ឈ្មោះ ហ៊ឹម ច័ន្ទគ្រីស្នា ភេទ ប្រុស អាយុ ២៥ ឆ្នាំ បានទៅចុះឈ្មោះបោះឆ្នោតនៅសង្កាត់ បឹងព្រលឹត ហើយឈ្មោះនេះខ្វះឯកសារបញ្ជាក់ទីលំនៅ ហើយបានទៅសុំបញ្ជាក់ទីលំនៅ ពីចៅសង្កាត់ ប៉ុន្តែចៅសង្កាត់មិនបញ្ជាក់ជូនដោយអះអាងថា ឈ្មោះនេះមិនមានទីលំនៅក្នុងសង្កាត់នេះទេ ។ ឈ្មោះ ច័ន្ទគ្រីស្នា នេះបានប្រគល់សិទ្ធិឱ្យលោក ឃឹម សត្ថា ដើម្បីធ្វើជាតំណាងក្នុងការប្តឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោតនៅក្នុងសង្កាត់ បឹងព្រលឹត ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ ប៉ុន្តែក្នុងពាក្យបណ្តឹង លោក ឃឹម សត្ថា បែរជាប្តឹងលោកស្រីចៅសង្កាត់ បឹងព្រលឹត ឈ្មោះ តៅ មន្ថា ពីបទរារាំងប្រជាពលរដ្ឋមិនឱ្យចុះឈ្មោះបោះឆ្នោតទៅវិញ ។

BtmanbEnmsmTnakTngTrsBe l x³ 023 214 374 / 012 855 018 E-mail: necinfo@forum.org.kh, Web-site : www.necelect.org.kh